## *កិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី ១៥*

ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, នាល្ងាចថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់បន្តចូលរួមកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី ១៥ តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះត្រូវបានដឹកនាំដោយឯកឧត្តម **ង្វៀន ស្វួន ហ៊្វុក (Nguyen Xuan Phuc)** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

កិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី ១៥ បានផ្តោតការពិភាក្សាទៅលើការពង្រឹងស្មារតីសាមគ្គីភាព និង កិច្ចសហប្រតិបត្តិការអន្តរជាតិរវាងប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ា និងភាគីពាក់ព័ន្ធដទៃទៀត ក្នុងការដោះស្រាយបញ្ហានានា ដែលបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩, ការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ តាមរយៈការប្រកាន់ជំហរពាណិជ្ជកម្មសេរី និងការតភ្ជាប់ឡើងវិញនូវខ្សែច្រវាក់ផ្គត់ផ្គង់ និងផលិតកម្ម ក៏ដូចជា វិហ្វូរវិនិយោគនៅក្នុងតំបន់ ។

ថ្នាក់ដឹកនាំអាស៊ីបូព៌ា បានធ្វើការវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃការអនុវត្តយន្តការនៅក្នុងតំបន់ដែលមានស្រាប់ដូចជា **"ផែនការសកម្មភាពទីក្រុងម៉ានីល (២០១៨-២០២២)"** និងគាំទ្រចំពោះគំនិតផ្តួចផ្តើមថ្មីៗដូចជា ការបង្កើតប្រព័ន្ធនៃការព្រមានទុកជាមុន (Early Warning System) ចំពោះការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត, កិច្ចសហប្រតិបត្តិការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ, និងការបង្កើនវប្បធម៌ចែករំលែកនៅក្នុងតំបន់ចំពោះបច្ចេកវិទ្យា, ចំណេះដឹង និងជំនាញក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត ក៏ដូចជាការស្តារសង្គម-សេដ្ឋកិច្ច ឡើងវិញ ។

ថ្នាក់ដឹកនាំនៃប្រទេសអាស៊ីបូព៌ាបានសម្តែងនូវការគាំទ្រ និងប្តេជ្ញាចិត្តខ្ពស់ក្នុងការកសាងអនាគតតមួយប្រកបដោយសន្តិភាព, វិបុលភាព, ស្ថេរភាព, ចីរភាព និងបរិយាប័ន្ន ដោយប្រកាន់ខ្ជាប់នូវស្មារតីពហុភាគីនិយម និងការដោះស្រាយបញ្ហាសកល ដោយសន្តិវិធី ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ។ ក្នុងស្មារតីនេះ, ថ្នាក់ដឹកនាំអាស៊ីបូព៌ាបានគាំទ្រនូវការរក្សាសុខសន្តិភាព និងដំណោះស្រាយដោយសន្តិវិធីនៅក្នុងឧបទ្វីបកូរ៉េ និងសមុទ្រចិនខាងត្បូង ក៏ដូចជានៅតំបន់វិវាទដទៃទៀត ។ ជាមួយគ្នានេះ, ថ្នាក់ដឹកនាំអាស៊ីបូព៌ាបានគូសបញ្ជាក់ពីសារសំខាន់នៃការស្រាវជ្រាវ និងផលិតវ៉ាក់សាំងនៃជំងឺកូវីដ-១៩ ក៏ដូចជាការកំណត់ថាវ៉ាក់សាំងនេះនឹងក្លាយជា **"ទំនិញសាធារណៈសកល** (Global Public Goods)" ដែលនឹងត្រូវបានចែកចាយដោយសមធម៌ និងក្នុងតម្លៃសមរម្យ ។ ថ្នាក់ដឹកនាំអាស៊ីបូព៌ាក៏បានសម្តែងនូវឆន្ទៈមោះមុតក្នុងការបម្លែងវិបត្តិនេះ ឱ្យក្លាយទៅជាឱកាសនៃការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងបរិបទនៃការស្តារសង្គម-សេដ្ឋកិច្ចឱ្យកាន់តែប្រសើរ និងរឹងមាំ ។

ជាលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី ១៥, ថ្នាក់ដឹកនាំអាស៊ីបូព៌ា បានសម្រេចអនុម័តឯកសារសំខាន់ចំនួន ៥÷ ១. "សេចក្តីថ្លែងការណ៍ទីក្រុងហាណូយ ស្តីពីខួបអនុស្សាវរីយ៍លើកទី ១៥ នៃកិច្ចប្រជុំកំពូលអាស៊ី

ប៉ូពាិ”, ២. “សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំកិច្ចប្រជុំកំពូលអាស៊ីប៉ូពាិស្តីពីចីរភាពសមុទ្រ”, ៣. “សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីប៉ូពាិ ស្តីពីការពង្រឹងសមត្ថភាពរួម ក្នុងការបង្ការ និង ការឆ្លើយតបចំពោះជំងឺរាតត្បាត”, ៤. “សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីប៉ូពាិ ស្តីពីសហប្រតិបត្តិការក្នុងការបង្កើនកំណើននៃសេដ្ឋកិច្ចក្នុងតំបន់ប្រកបដោយស្ថិរភាព” និង ៥. “សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីប៉ូពាិ ស្តីពីស្ត្រី, សន្តិភាព និសន្តិសុខ” ។